# ពាក្យអារាធនាព្រះសង្ឃសម្ដែងធម៌ទេសនា

គ្រានោះសហម្បតី- ព្រហ្មជាឥសូលោកា
ចូលគល់ព្រះសាស្ដា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្ដេចទ្រង់ជ្រាប
ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្ទើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជាកប្ញសគល់ ជាបច្ច័យនៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រឹតរុំហ៊ុមជុំជាប់នៅ ។
ហេតុនេះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្ពោះទៅ ដាក់ត្រើយត្រាណនិព្វាននាយ ។
ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្ដរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បៃកដាស ។
អរិយសច្ចជាអន្លូង សម្រាប់ទូងឱ្យឮច្បាស់

សត្វលោកងោកងុយណាស់ ឮស្គរដាសក្រោកឡើងបាន ។
បរិស័ទ ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះដុះចាំសូរ្យឆាន រះនឹងរីកដោយរស្មី ។
ព្រះធម៌ជាសូរ្យសែង រះឡើងចែងចាំងរស្មី
បំភ្លឺលោកទាំងបី ឱ្យយល់ផ្លូវឋានសុខា ។
សហម្បតីព្រហ្ម ឱនបង្គំអារាធនា
សម្តេចព្រះភគវា ដោយគាថាយ៉ាងនេះឯង
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសម្តែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញុំាងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទិ៍
ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សម្តែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះឯងហោង ។

Edited by: Dejkun Wat Kraya
Wat Kraya, Kraya Commune, Santuk District,
Kampong Thom Province, Cambodia
E-mail: watkraya@gmail.com
Website: http://krayayouth.wordpress.com/
Phone: (+855) 62 690 5008